ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

លេខ : ០៤៤ សរ/គ.ឃ.ស

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០

សេចក្តីសំរេច
ស្តីពី
ការបង្កើតក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់
នៅថ្នាក់ខេត្ត ក្រុង

សហប្រធានគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- យោងប្រកាសលេខ ១៨៨៤ ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ រប[illegible]ក្សួងមហាផ្ទៃ ស្តីពីធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសំរេចលេខ ០០២ សសរ/គ.ឃ.ស ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៥ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ស្តីពីការបង្កើតក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់

សេចក្តីថ្លែង

ប្រការ ១.~ ការបង្កើតក្រុមការងារគណនេយ្យភាព

ត្រូវបានបង្កើតក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់នៅថ្នាក់ខេត្ត ក្រុង ដើម្បីពង្រឹងរាល់ការអនុវត្ត និងប្រើប្រាស់មូលនិធិឃុំ សង្កាត់ អោយមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ ។

ក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់នៅថ្នាក់ខេត្ត ក្រុង ត្រូវមានអាណត្តិការងារស្មើនឹងអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រការ ២.~ សមាជិកភាពរបស់ក្រុមការងារគណនេយ្យភាព

ក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់នៅថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម ÷

១- អភិបាលខេត្ត ក្រុង	ជាប្រធាន
២- អភិបាលរងទី១ ខេត្ត ក្រុង	ជាអនុប្រធាន
៣- ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង	ជាសមាជិក
៤- ប្រធានផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង	ជាសមាជិក
៥- ប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យារបស់គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង	ជាសមាជិក
៦- ប្រធានផ្នែកបច្ចេកទេសរបស់គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង	ជាសមាជិក
៧- ប្រធានរតនាគារខេត្ត ក្រុង	ជាសមាជិក
៨- តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិចំនួន ០១ រូប	ជាសមាជិក
៩- តំណាងអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការចំនួន ០១ រូប	ជាសមាជិក
១០- តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ០៣ រូប មកពីគ្រប់គណបក្សនយោបាយ ដែលមានអាសនៈក្នុងក្រុមប្រឹក្សាឃុំ សង្កាត់	ជាសមាជិក
១១- ប្រធានទីប្រឹក្សាកម្មវិធីសិលាប្រចាំខេត្ត ក្រុង	ជាសមាជិក
១២- សវនករផ្នែកក្នុងខេត្ត ក្រុង	ជាសមាជិការ

ប្រការ ៣.~ នីតិវិធីនៃការជ្រើសរើសតំណាងអោយចូលជាសមាជិកក្រុមការងារគណនេយ្យភាព

ការជ្រើសរើសតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងសង្គមស៊ីវិល និងតំណាងអ្នកទទួលការ ដោយចូលជាសមាជិកក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់នៅថ្នាក់ខេត្ត ក្រុង ត្រូវអនុវត្តតាមក្បួនខ្នាតដែលមានចែងក្នុងឧបសម្ព័ន្ធទី១ ។

ប្រការ ៤.- តួនាទី មុខងារ និងភារកិច្ចរបស់ក្រុមការងារគណនេយ្យភាព

ក្រុមការងារគណនេយ្យភាពនៅថ្នាក់ខេត្ត ក្រុង មានតួនាទី មុខងារ និងភារកិច្ចដូចខាងក្រោម÷

- ផ្សព្វផ្សាយអំពីគោលបំណង តួនាទី មុខងារ និងភារកិច្ច ព្រមទាំងនីតិវិធីធ្វើការងាររបស់ខ្លួនអោយបានទូលំទូលាយដល់គ្រប់អ្នកពាក់ព័ន្ធទៅនឹងការប្រើប្រាស់មូលនិធិឃុំ សង្កាត់
- ប្រមូលរបាយការណ៍ និងពាក្យបណ្តឹងតវ៉ាស្តីពីបញ្ហាមិនមានគណនេយ្យភាពនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងរក្សានូវការសម្ងាត់
- ពិនិត្យ និងពិភាក្សាគ្រប់របាយការណ៍ ព័តមាន និងបណ្តឹងតវ៉ាទាំងអស់ ដែលទាក់ទងនឹងបញ្ហាមិនមានគណនេយ្យភាពនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់
- ពិនិត្យរបាយការណ៍សវនកម្មបច្ចេកទេសប្រចាំឆ្នាំដោយប្រុងប្រយ័ត្ន និងតាមដានបញ្ហានានាដែលបានលើកឡើងនៅក្នុងរបាយការណ៍
- មិនត្រូវព្យួរទុកករណីណាមួយពាក់ព័ន្ធនឹងបញ្ហាមិនមានគណនេយ្យភាពលើសពីមួយខែឡើយ
- រៀបចំ និងចុះស៊ើបអង្កេតបញ្ហានានាដែលបានលើកឡើងនៅក្នុងរបាយការណ៍ ក្នុងករណីចាំបាច់
- កំណត់វិធានការដាក់វិន័យ ឬទណ្ឌកម្ម ចំពោះបុគ្គលណាដែលមានការពាក់ព័ន្ធនឹងបញ្ហាមិនមានគណនេយ្យភាពនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់
- ស្នើសុំទៅក្រសួងស្ថាប័ន ឬអង្គភាពសាមី ដើម្បីដាក់វិន័យ ឬទណ្ឌកម្មចំពោះបុគ្គលណាដែលបានប្រព្រឹត្តិសកម្មភាពពាក់ព័ន្ធនឹងបញ្ហាមិនមានគណនេយ្យភាពនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់
- ត្រូវពិនិត្យយ៉ាងប្រុងប្រយ័ត្នអំពីនីតិវិធានុកូលភាពនៃការដាក់វិន័យ ឬទណ្ឌកម្មទាំងនោះ (ផ្អែកទៅលើច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ)
- ធានាអោយបាននូវការអនុវត្តវិធានការដាក់វិន័យ ឬទណ្ឌកម្មនានាដែលបានកំណត់រួចហើយ
- ត្រូវដាក់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ដើម្បីពិនិត្យ និងសំរេច ចំពោះសំណើរបស់ឃុំ សង្កាត់ណាដែលខ្លួនមិនអាចសំរេចបាន
- ត្រូវអនុវត្តទៅតាមអនុសាសន៍របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- ត្រូវរាយការណ៍អំពីការអនុវត្តការងាររបស់ខ្លួន ជូនក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ កម្មាធិការជាតិ និងគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

ប្រការ ៥.~ ការទទួល និងផ្សព្វផ្សាយព័ត៌មាន

ក្រុមការងារគណនេយ្យភាពនៅថ្នាក់ខេត្ត ក្រុង ត្រូវចែកចាយ និង ផ្សព្វផ្សាយនូវសន្លឹកបណ្ណព័ត៌មាន ស្តីពីគណនេយ្យភាព ដែលនឹងត្រូវបានរៀបចំដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

ក្រុមការងារគណនេយ្យភាពនៅថ្នាក់ខេត្ត ក្រុង ត្រូវរៀបចំ "**ប្រអប់សំបុត្រគណនេយ្យភាពមូលនិធិឃុំ សង្កាត់**" ដោយដាក់នៅការិយាល័យគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ការិយាល័យតំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋានខេត្ត ក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដើម្បីទទួលបាននូវព័ត៌មានស្តីពីបញ្ហាមិនមានគណនេយ្យភាពនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ ។ គ្រប់កន្លែងដាក់ប្រអប់សំបុត្រគណនេយ្យភាពមូលនិធិឃុំ សង្កាត់ទាំងអស់ ត្រូវមានសន្លឹកបណ្ណព័ត៌មានស្តីពីគណនេយ្យភាពសំរាប់ផ្សព្វផ្សាយ និងចែកជូនផងដែរ ។

ប្រការ ៦.~ សិទ្ធិចាត់តាំងសមាជិក និងមន្ត្រីពាក់ព័ន្ធក្នុងការបំពេញការងារ

ក្នុងករណីមានបញ្ហា ឬមានបណ្តឹងតវ៉ាណាមួយដែលត្រូវការស៊ើបអង្កេត ឬពិនិត្យ ប្រធានក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់នៅថ្នាក់ខេត្ត ក្រុង អាចចាត់តាំងសមាជិកក្រុមការងារគណនេយ្យភាពណាម្នាក់ ដើម្បីឱ្យទទួលខុសត្រូវចំពោះករណីនីមួយៗនោះ ។

ក្រុមការងារគណនេយ្យភាពត្រូវចាត់តាំងមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ដើម្បីប្រមូលរបាយការណ៍ ព័ត៌មាន ឬបណ្តឹងតវ៉ាទាំងអស់អោយបាននៅក្នុងសប្តាហ៍ចុងក្រោយនៃខែនីមួយៗ ។

អ្នកប្រមូលរបាយការណ៍ ព័ត៌មាន ឬបណ្តឹងតវ៉ាពីប្រអប់សំបុត្រ មិនអនុញ្ញាតអោយបើកស្រោមសំបុត្រទាំងនោះ ដោយមិនមានវត្តមានសមាជិកក្រុមការងារគណនេយ្យភាពដែលមានសមត្ថកិច្ចនោះឡើយ ។ របាយការណ៍ ព័ត៌មាន ឬបណ្តឹងតវ៉ាទាំងអស់ដែលប្រមូលបាន ត្រូវតែចុះក្នុងស្មៀវភៅបញ្ជីរបស់ក្រុមការងារគណនេយ្យភាព ។ ក្រុមការងារគណនេយ្យភាពត្រូវពិនិត្យ និងសំរេចជ្រើសរើសរបាយការណ៍ ព័ត៌មាន ឬបណ្តឹងតវ៉ាណាដែលចាំបាច់ត្រូវធ្វើការពិភាក្សា ឬស៊ើបអង្កេត ។

ប្រការ ៧.~ ភារតួកិច្ចរបស់សមាជិកក្រុមការងារគណនេយ្យភាព

សមាជិកក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់នៅថ្នាក់ខេត្ត ក្រុង ត្រូវតែអនុវត្តតាមការណែនាំដូចមានចែងក្នុងសេចក្តីសំរេចនេះ ព្រមទាំងធានាថាគ្រប់អ្នកពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់មូលនិធិឃុំ សង្កាត់ទាំងអស់ទទួលបានសន្លឹកបណ្ណព័ត៌មានខាងលើ ។ អ្នកពាក់ព័ន្ធទាំងអស់នោះរួមមាន ÷

- មន្ត្រីរតនាគារខេត្ត ក្រុង

- សមាជិកគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង
- ប្រធាន និងអនុប្រធានមន្ទីរជំនាញជុំវិញខេត្ត ក្រុង
- អ្នកសំរបសំរួលខេត្ត ក្រុង និងស្រុក ខណ្ឌ
- មន្ត្រីគាំទ្របច្ចេកទេស
- អភិបាល និងអភិបាលរងស្រុក ខណ្ឌ
- អ្នកទទួលការ
- អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលធ្វើការងារនៅក្នុងខេត្ត ក្រុងរបស់ខ្លួន
- គ្រប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- ស្មៀនឃុំ សង្កាត់
- សមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់
- ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតំលៃរបស់ឃុំ សង្កាត់ និង
- សមាជិកគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ ។

ប្រការ ៨.- សិទ្ធិរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា

ប្រជាពលរដ្ឋគ្រប់រូប និងអ្នកពាក់ព័ន្ធទាំងអស់ មានសិទ្ធិរាយការណ៍ស្តីពីបញ្ហាមិនមានគណនេយ្យភាពនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់តាមរយៈសន្លឹកប័ណ្ណព័ត៌មានស្តីពីគណនេយ្យភាព ឬតាមរយៈមធ្យោបាយផ្សេងទៀត ហើយយកទៅដាក់នៅក្នុង "**ប្រអប់សំបុត្រគណនេយ្យភាពមូលនិធិឃុំ សង្កាត់**" ដែលនៅជិតផ្ទះរបស់ខ្លួន។ លើសពីនេះទៀត ប្រជាពលរដ្ឋគ្រប់រូប និងអ្នកពាក់ព័ន្ធទាំងអស់អាចរាយការណ៍ផ្ទាល់មាត់ជូនទៅសមាជិកក្រុមការងារគណៈនេយ្យភាពណាម្នាក់ក៏បាន។ ក្នុងករណីនេះ ដោយផ្អែកតាមការរាយការណ៍ផ្ទាល់មាត់ (រួមទាំងការរាយការណ៍តាមទូរស័ព្ទផង) សមាជិកក្រុមការងារគណនេយ្យភាពរូបនោះ ត្រូវតែរៀបចំរបាយការណ៍ដើម្បីដាក់ជូនកិច្ចប្រជុំរបស់ក្រុមការងារគណនេយ្យភាពសំរាប់ការពិភាក្សា និងសម្រេច។

ប្រការ ៩.- របៀបរបបប្រជុំរបស់ក្រុមការងារគណនេយ្យភាព

ក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់នៅថ្នាក់ខេត្ត ក្រុងត្រូវធ្វើការប្រជុំយ៉ាងតិចបំផុតមួយដងក្នុងមួយខែ។ គ្រប់កិច្ចប្រជុំរបស់ក្រុមការងារគណនេយ្យភាព ត្រូវតែដឹកនាំដោយប្រធាន។ ក្នុងករណី ប្រធានមិនត្រៅមានអនុប្រធាននឹងត្រូវដឹកនាំកិច្ចប្រជុំនេះតាមរយៈការប្រគល់សិទ្ធិ។

កិច្ចប្រជុំរបស់ក្រុមការងារគណនេយ្យភាព ត្រូវមានលិខិតអញ្ជើញដោយភ្ជាប់មកជាមួយនូវរបៀបវារៈ រួមជាមួយ

ត្រូវចែកជូនគ្រប់សមាជិកក្រុមការងារគណនេយ្យភាពអោយបាន ២ថ្ងៃមុនការប្រជុំ។

កិច្ចប្រជុំក្រុមការងារគណនេយ្យភាពនឹងយកជាការបាន លុះត្រាតែមានវត្តមានសមាជិកក្រុមការងារគណនេយ្យភាពលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមការងារគណនេយ្យភាពទាំងអស់។

សេចក្តីសម្រេចនៃអង្គប្រជុំរបស់ក្រុមការងារគណនេយ្យភាពដែលចាត់ទុកជាបានការ លុះត្រាតែសេចក្តីសំរេចនោះ ត្រូវបានអនុម័តដោយសម្លេងភាគច្រើននៃចំនួនសមាជិកក្រុមការងារគណនេយ្យភាពដែលបានចូលរួមប្រជុំ។

ក្នុងពេលអនុម័ត ប្រសិនបើមានសម្លេងឆ្នោតស្មើគ្នា សម្លេងរបស់ប្រធាននៃអង្គប្រជុំមានឧត្តមានុភាព។

ក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ថ្នាក់ជាតិមានសិទ្ធិចូលរួមដើម្បីពិនិត្យ និងសង្កេតកិច្ចប្រជុំរបស់ក្រុមការងារគណនេយ្យភាពមូលនិធិនៅថ្នាក់ខេត្ត ក្រុង។

ប្រការ ១០.- វិធានការដាក់វិន័យ ឬទណ្ឌកម្ម

នៅក្នុងកិច្ចប្រជុំលើកទីមួយរបស់ខ្លួន ក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់នៅថ្នាក់ខេត្ត ក្រុង ត្រូវរៀបចំ និងអនុម័តលើវិធានការដាក់វិន័យ ឬទណ្ឌកម្ម ចំពោះបុគ្គលណាដែលមានការពាក់ព័ន្ធនឹងបញ្ហាមិនមានគណនេយ្យភាពនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់។

ក្រុមការងារគណនេយ្យភាពនៅថ្នាក់ខេត្ត ក្រុង ត្រូវផ្ញើជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ថ្នាក់ជាតិ នូវវិធានការដាក់វិន័យ ឬទណ្ឌកម្មដែលបានអនុម័ត។

ដើម្បីជាជំនួយដល់ក្រុមការងារគណនេយ្យភាពនៅថ្នាក់ខេត្ត ក្រុង គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់បានរៀបចំគំរូវិធានការដាក់វិន័យ ឬទណ្ឌកម្មមួយចំនួន ដូចមានបរិយាយក្នុងឧបសម្ព័ន្ធទី ២។

ប្រការ ១១.- ការអនុវត្តសេចក្តីសំរេចរបស់ក្រុមការងារគណនេយ្យភាព

ក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុង ត្រូវផ្ញើសេចក្តីសំរេចរបស់ខ្លួនទៅឱ្យដល់ផ្នែក និងអង្គភាពនៃគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង មន្ទីរជំនាញជុំវិញខេត្ត ក្រុង និងស្ថាប័នពាក់ព័ន្ធនានា យ៉ាងយូរក្នុងរយៈពេល ៥ ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីសេចក្តីសំរេចនោះបានអនុម័ត។

ផ្នែក និងអង្គភាពនៃគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង មន្ទីរជំនាញជុំវិញខេត្ត ក្រុង និងស្ថាប័នពាក់ព័ន្ធ ត្រូវតែអនុវត្តតាមឱ្យបានម៉ឺងម៉ាត់នូវសេចក្តីសំរេចនៃអង្គប្រជុំរបស់ក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុង យ៉ាងយូរក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីសំរេចនេះ។

ប្រការ ១២.- ការជួលទីប្រឹក្សាច្បាប់

គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង ត្រូវគ្រោងថវិកាមួយចំនួនសំរាប់ជួលទីប្រឹក្សាច្បាប់ ឬមន្ត្រីជំនាញ ដើម្បីផ្តល់

យោបល់អំពីទិដ្ឋភាពច្បាប់ និងការពារសេចក្តីសំរេចរបស់ក្រុមការងារគណនេយ្យភាពនៅថ្នាក់ខេត្ត ក្រុង ក្នុងករណីដែលសេចក្តីសំរេចនោះត្រូវបានបញ្ជូនទៅតុលាការ។ ការជួលនេះអាចធ្វើឡើង យោងតាមពេលវេលា និងករណីចាំបាច់ ដោយមានលក្ខខ័ណ្ឌការងារច្បាស់លាស់ ។

ប្រការ ១៣.- ការិយាល័យរបស់ក្រុមការងារគណនេយ្យភាព

ការិយាល័យក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់នៅថ្នាក់ខេត្ត ក្រុង មានទីតាំងនៅក្នុងការិយាល័យគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង។ ចំណាយសំរាប់ការបង្កើត និងប្រតិបត្តិការរបស់ក្រុមការងារគណនេយ្យភាពនៅថ្នាក់ខេត្ត ក្រុង ត្រូវចំណាយតាមរយៈថវិការបស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ដោយមានខ្លង់ថវិកាជាក់លាក់មួយដែលត្រូវបានផ្តល់ជូន។ ការចំណាយប្រតិបត្តិការ រួមមានការចំណាយសំរាប់ការប្រជុំ ការចុះស៊ើបអង្កេត និងការទំនាក់ទំនងនានា។

អភិបាលខេត្ត ក្រុង មន្ទីរជំនាញជុំវិញខេត្ត ក្រុង និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ.គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

សហប្រធាន

ឯកឧត្តម.សិរិតន្ត្រីឈ្យ

ចំលងជូន :

- ក្រសួងជាសមាជិក គ.ឃ.ស
- គណៈកម្មាធិការដឹកនាំកម្មវិធីសិលា
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ